ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**KINGDOM OF CAMBODIA**

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

**Ministry of Commerce**

No. ១០៤ MOC / SM 2008

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការបំពេញប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនពាណិជ្ជកម្ម

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៦៩៥/ ០៤ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១១៩៩/ ១២ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៦០៥/ ០១៩ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់ ក្នុងទិសដៅកែទំរង់វិស័យចុះបញ្ជីពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្ម

## សំរេច

**ប្រការ ១ :** រាល់ក្រុមហ៊ុន ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម មានកាតព្វកិច្ចតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

**ប្រការ ២ :** ការិយាល័យប្រតិវេទន៍នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មមានកាតព្វកិច្ចផ្តល់គំរូប្រតិវេទន៍ជូនក្រុមហ៊ុន ដើម្បីថតចំលង ហើយបំពេញខ្លឹមសារដោយខ្លួនឯង ដើម្បីយកមកតំកល់ទុកនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មដោយឥតគិតថ្លៃ ។



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០១
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ : (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៤ ៩៤៦
ទូរសារលេខ : (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@vahoo.com

Downloaded from http://www.khmerlaws.com

**ប្រការ ៣ៈ** មន្ត្រីការិយាល័យប្រតិវេទន៍មានកាតព្វកិច្ចទទួលតំកល់ទុក ចុះលេខ និងប្រថាប់ត្រាលើប្រតិវេទន៍ និងជួយសំរួលបំពេញប្រតិវេទន៍ជូនដល់ក្រុមហ៊ុនអោយបានត្រឹមត្រូវ ។

**ប្រការ ៤ៈ** ក្រុមហ៊ុនទាំងឡាយណា ដែលខកខានមិនបានយកប្រតិវេទន៍ប្រចាំឆ្នាំមកតំកល់ទុក នៅដំណាច់ឆ្នាំនិមួយៗ នឹងត្រូវទទួលការផាកពិន័យ ស្របទៅតាមមាត្រា ២៩០ និង មាត្រា ២៩៤ នៃច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម ។ ប្រាក់ដែលប្រមូលបានមកអំពីការផាកពិន័យនេះ ត្រូវបង្វិលចូលថវិការដ្ឋ ។

**ប្រការ ៥ៈ** ក្រុមហ៊ុនទាំងឡាយណា ដែលខកខានមិនបានយកប្រតិវេទន៍មកតំកល់ទុក ក្នុងអំឡុងពេល បីឆ្នាំ (៣ឆ្នាំ) បន្តបន្ទាប់ នឹងត្រូវចាត់ទុកថាជាក្រុមហ៊ុនមិនស្របច្បាប់ ។

រាល់ឯកសារបញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ដែលក្រសួងពាណិជ្ជកម្មបានចេញជូនក្រុមហ៊ុន នឹងត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦ៈ** រាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលប្រើប្រាស់ឯកសារក្លែងក្លាយដោយចេតនា នៅក្នុងទំនាក់ទំនងពាណិជ្ជកម្ម នឹងត្រូវផ្តន្ទាទោសស្របទៅតាមមាត្រា៤៣ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

**ប្រការ ៧ៈ** ប្រកាសរបស់ក្រសួងពាណិជ្ជកម្មលេខ ១៤៩ MOC / SM 2006 ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ២០០៦ ស្តីពីការបំពេញប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨ៈ** អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នាយកដ្ឋាននីតិកម្ម មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុងទាំងអស់ ត្រូវអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ តាមខ្លឹមសារនៃសេចក្តីប្រកាសនេះ ។

**ប្រការ ៩ៈ** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ.ថ្ងៃទី.០៧.ខែ.០៤..ឆ្នាំ២០០៨

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម_សម្បត្តិ

ចម្លងជូន :

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង**
- ទីស្តីការគណៈរដ្ឋមន្ត្រី " ជូនជ្រាបជារបាយការណ៍ "
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ "ដើម្បីជូនជ្រាប"
- សាលាខេត្ត-ក្រុង ដើម្បីជួយផ្សព្វផ្សាយ
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- ឯកសារ - កាលប្បវត្តិ



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ : (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៤ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

Downloaded from http://www.khmerlaws.com